ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...... សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ...ខែ...ឆ្នាំ ២០១១

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**

**កម្មវត្ថុ:** សំណើសុំគោលការណ៍ចំណាយថវិកាជំពូក ២១« គម្រោងវិនិយោគផ្ទាល់» ចំនួន ៧ ៨៤០ ៤១៣ ៦៦៦រៀល ជូននាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ស្តារប្រព័ន្ធស្រោចស្រពកោជន្លីង ស្ថិតក្នុងឃុំកោជន្លីង ឃុំជ័យធំ និងឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- លិខិតលេខ ២៥៦ ធទឧ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្តល់ជានាចំណាយជូនចំនួន ៧ ៦៧១ ០០០ ០០០រៀល (ប្រាំពីពាន់ប្រាំមួយរយចិតសិបមួយលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ «គម្រោងវិនិយោគផ្ទាល់» សម្រាប់ឲ្យនាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម អនុវត្តការងារស្តារប្រព័ន្ធស្រោចស្រពកោជន្លីង ស្ថិតក្នុងឃុំកោជន្លីង ឃុំជ័យធំ និងឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល រួមមាន៖

-ស្តារប្រឡាយទួលគោកកាយ ប្រវែង ៤.០១៥ម និងសាងសង់សំណង់សិល្បការ ចំនួន ២៣កន្លែង
-ស្តារប្រឡាយចកទួលកាផ្លា ប្រវែង១.៩៨០ម និងសាងសង់សំណង់សិល្បការ ចំនួន ៤កន្លែង
-ជួសជុលផ្លូវចូលទំនប់អាងទឹកអង្គ្រង ប្រវែង ៥០០ម
-ជួសជុលទំនប់អាងទឹកអង្គ្រង ប្រវែង ២.៨៥០ម និងសាងសង់សំណង់សិល្បការ ចំនួន ៧កន្លែង
-ជួសជុលផ្លូវចូលទំនប់អាងទឹកប្រមូលខ្លា ប្រវែង ២៥០ម
-ជួសជុលទំនប់អាងទឹកប្រមូលខ្លាប្រវែង៣.៩៨០ម និងសាងសង់សំណង់សិល្បការ ចំនួន ៧កន្លែង

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។
សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***ចម្លងជូន***
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ* **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តកណ្តាល
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្តាល
- នាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ »
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com